CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១៨ ខែមិថុនាឆ្នាំ ២០២០

ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចបានប្រកាសពីកំណត់ពេលវេលាសម្រាប់ការបើកឡើងវិញនៃបារនិងហាងថែសម្ផស្សនិងថែខ្លួន

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - មន្ត្រីទីក្រុងបានប្រកាសនៅថ្ងៃនេះថានឹងអនុញ្ញាតឱ្យបារនិងហាងធ្វើក្រចកបើកឡើងវិញនៅថ្ងៃសុក្រទី ១៩ ខែមិថុនាប្រសិនបើពួកគាត់បំពេញតាមតម្រូវការផ្នែកអនាម័យនិងការអនុវត្តរាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នាដើម្បីការពារពីការរីករាលដាលនៃ COVID-19។ ពិធីសាសនានិងពិធីវប្បធម៌ដូចជាពិធីបុណ្យសពឥឡូវនេះអាចប្រារព្ធបាននៅខាងក្រៅដោយមានការកែសំរួលមួយចំនួន។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "យើងបន្តបើកដំណើរការសេដ្ឋកិច្ចជាបណ្តើរៗដោយសុវត្ថិភាពដែលផ្អែកលើទិន្នន័យមន្ទីរពេទ្យដែលមានស្ថេរភាព។ សូមទទួលខុសត្រូវដោយអនុវត្តរាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នាពាក់របាំងមុខនិងធ្វើតាមការណែនាំរបស់អ្នកជំនាញផ្នែកសុខភាព។"

បារនិងកន្លែងធ្វើស្រាទំពាំងបាយជូរអាចបើកឡើងវិញបានត្រឹមចំណុះ ៥0 ភាគរយនៃហាងតែប៉ុណ្ណោះហើយកន្លែងបារត្រូវបិទនិងមិនអនុញ្ញាតឱ្យមានកន្លែងឈរទេ។ អតិថិជនអាចប្រើកន្លែងអង្គុយតាមភោជនីយដ្ឋានបាន។ អតិថិជនត្រូវពាក់របាំងមុខនៅពេលចូលទៅក្នុងទីតាំងឬធ្វើដំណើរពីកន្លែងមួយទៅ

កន្លែងមួយនៅក្នុងហាងហើយអ្នករត់តុត្រូវពាក់របាំងមុខនិងខែលការពារមុខពេលដែលបម្រើដល់អតិថិជនដែលមិនបានពាក់របាំងមុខ។

ហាងធ្វើក្រចកអាចបើកជាថ្មីដោយមានការរឹតត្បិតមួយចំនួននិងដោយអនុវត្តពិធីសារសុវត្ថិភាពត្រឹមត្រូវដូចជាការបង្កើតចម្ងាយ ៦ ហ្វីតរវាងស្ថានីយសេវាកម្មនីមួយៗការទាមទារឱ្យទាំងនិយោជិកនិងអតិថិជនពាក់របាំងមុខការធ្វើអនាម័យជាញឹកញាប់លើផ្ទៃដែលប៉ះខ្ពស់និងការកំណត់ចំនួនអតិថិជនក្នុងពេលតែមួយ។

លើសពីនេះទៀតបទបញ្ជាសុខភាពនឹងមានការកែសំរួលសម្រាប់ពិធីសាសនានិងពិធីវប្បធម៌ដែលប្រារព្ធនៅខាងក្រៅ។ មិនមានការកំណត់លើចំនួនអតិបរមានៃអ្នកចូលរួមពិធីសាសនាឬពិធីវប្បធម៌ដែលប្រារព្ធនៅខាងក្រៅទេ (ជាឧទាហរណ៍ពិធីបុណ្យសព) ប៉ុន្តែអ្នកចូលរួមត្រូវតែមានកន្លែងទំនេរគ្រប់គ្រាន់ដើម្បីរក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នាក្នុងចម្ងាយយ៉ាងហោចណាស់ប្រាំមួយហ្វីតរវាងអ្នកដែលមិនរស់នៅក្នុងផ្ទះតែមួយ។ ពិធីសាសនាដែលប្រារព្ធនៅខាងក្នុងនៅតែមានកំណត់ត្រឹម ២៥ ភាគរយនៃចំណុះអគារឬចំនួនអ្នកចូលរួមត្រឹមតែ ១០០ នាក់។ ត្រូវតែកំណត់តាមចំនួនណាមួយដែលតិចជាង។

ពិធីសារសុវត្ថិភាពដែលត្រូវអនុវត្តនឹងចែងនៅក្នុងបទបញ្ជាសុខភាពដែលបានកែប្រែដែលនឹងចេញនាពេលខាងមុខ។

ចាប់ពីថ្ងៃទី ២៦ ខែមិថុនាសេវាកម្មថែសម្ផស្សនិងថែខ្លួន (ជាឧទាហរណ៍៖ ហាងសាក់លើស្បែក សេវាកម្មគ្រឿងសំអាង ការដករោមពីខ្លួនដោយប្រើក្រមួន ស្ប៉ានិងការព្យាបាលដោយម៉ាស្សានៅកន្លែងដែលមិនមែនជាកន្លែងព្យាបាលសុខភាព អ្នកជំនាញខាងសិល្បៈរាងកាយនិងហាងចោះ) នឹងត្រូវអនុញ្ញាតឱ្យបើកដំណើរការឡើងវិញដោយមានការរឹតត្បិតមួយចំនួននិងត្រូវមានការអនុវត្តពិធីសារសុវត្ថិភាពត្រឹមត្រូវ។ សេវាកម្មថែសម្ផស្សនិងថែខ្លួនទាំងនេះច្រើនតែពាក់ព័ន្ធនឹងសកម្មភាពទល់មុខគ្នាក្នុងរយៈពេលយូរដោយមិនអាចរក្សាចម្ងាយពីគ្នាបាន។ ជារឿយៗសម្រាប់សេវាកម្មទាំងនេះអ្នកដែលទទួលសេវាកម្មមិនបានពាក់របាំងមុខទេ។ មន្ត្រីសុខាភិបាលក្រុងបានកំណត់ថាទាំងនេះជាសកម្មភាពដែលមានហានិភ័យខ្ពស់។ ដូច្នេះទីក្រុងកំពុងរង់ចាំមួយសប្តាហ៍បន្ថែមទៀតមុននឹងអនុញ្ញាតឱ្យអាជីវកម្មថែសម្ផស្សនិងថែខ្លួនទាំងនេះបើកដំណើរការឡើងវិញដើម្បីផ្តល់ឱកាសឱ្យអាជីវកម្មទាំងនេះរៀបចំកន្លែងនានាដើម្បីអនុ

វត្តតាមវិធានការទប់ស្កាត់ការឆ្លងនិងអនុវត្តពិធីសារសុវត្ថិភាពឱ្យបានត្រឹមត្រូវមុនពេលបើកដំណើរការឡើងវិញ។

អាជីវកម្មខាងក្រោមត្រូវបិទនៅឡុងប៊ិចរហូតដល់មានការជូនដំណឹងបន្ថែម៖

- រោងកុន
- មជ្ឈមណ្ឌលកម្សាន្តជាលក្ខណៈគ្រួសារដូចជាកន្លែងបោះប៊ូលកន្លែងវាយកូនហ្គោលខ្នាតតូចនិងកន្លែងលេងល្បែងអេកខៃតសម្រាប់ក្មេង

សកម្មភាពនេះត្រូវបានបង្កើតឡើងដោយមន្ត្រីសុខាភិបាលទីក្រុងគឺវេជ្ជបណ្ឌិត Anissa Davis និងយោងទៅតាមអំណាចបន្ទាន់ (Emergency Powers) ដែលផ្តល់ទៅឱ្យអ្នកគ្រប់គ្រងក្រុងតាមរយៈការប្រកាសអាសន្នក្នុងតំបន់ (Proclamation of Local Emergency)។ បទបញ្ជានេះមានប្រសិទ្ធភាពភ្លាមៗនៅថ្ងៃទី ១២ ខែមិថុនាឆ្នាំ ២០២០ ហើយនឹងបន្តរហូតដល់បទបញ្ជានេះត្រូវបានពន្យារពេលដកហូតវិញឬកែប្រែជាលាយលក្ខណ៍អក្សរដោយមន្ត្រីសុខាភិបាល។

បទបញ្ជាសុខភាពដែលត្រូវបានធ្វើបច្ចុប្បន្នភាពនឹងត្រូវតម្រឹមនឹងផែនទីបង្ហាញផ្លូវភាពរឹងប៉ឹងរបស់ខោនធីនិងរដ្ឋកាលីហ្វ័រញ៉ា។ ម្ចាស់អាជីវកម្មត្រូវបានលើកទឹកចិត្តឱ្យពិនិត្យមើលគោលការណ៍ណែនាំរបស់រដ្ឋមុនពេលដែលបទបញ្ជាសុខភាពឡុងប៊ិចដែលបានធ្វើវិសោធនកម្មនាពេលខាងមុខនេះចេញ។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

\# # #